# ធនាគារជាតិ នៃ កម្ពុជា

## ព្រឹត្តិបត្រប្រចាំត្រីមាស



## លេខ ៣៧

## ត្រីមាសទី៣ ឆ្នាំ២០១១

ចេញផ្សាយតាមប្រកាសលេខ ធ១-០២-១២៦ ប្រ.ក ចុះថ្ងៃទី០២ ខែមេសា ឆ្នាំ២០០២

បោះពុម្ពផ្សាយដោយ

# ធនាគារជាតិ នៃ កម្ពុជា

| | | |
|---|---|---|
| អាសយដ្ឋាន | : | ២២-២៤ មហាវិថីព្រះនរោត្តម ភ្នំពេញ កម្ពុជា |
| ប្រអប់សំបុត្រ | : | ២៥ |
| ទូរស័ព្ទ | : | (៨៥៥) ២៣ ៧២២ ៥៦៣ |
| ទូរសារ | : | (៨៥៥) ២៣ ៤២៦ ១១៧ |
| គេហទំព័រ | : | www.nbc.org.kh |

*********

Published by

# National Bank of Cambodia

| | | |
|---|---|---|
| Address | : | 22-24 Preah Norodom Blvd.<br>Phnom Penh, Cambodia |
| P.O.BOX | : | 25 |
| Phone | : | (855) 23 722 563 |
| FAX | : | (855) 23 426 117 |
| Website | : | www.nbc.org.kh |


| គណៈកម្មការព្រឹត្តិបត្រ | | Review Commission | |
|---|---|---|---|
| - ឯកឧត្តម ថា យ៉ាវ | ប្រធាន | H.E. Tha Yao | Chairman |
| - ឯកឧត្តម ស៊ុំ សន្និសិទ្ធ | និពន្ធនាយក | H.E. Dr.Sum Sannisith | Chief Editor |

# អារម្ភកថា



## ឯកឧត្តម ជា ចាន់តូ
## ទេសាភិបាលធនាគារជាតិនៃកម្ពុជា

*ប្រិយមិត្តអ្នកអានជាទីមេត្រី !*

ពីរឆ្នាំបន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកល ស្ថានភាពសេដ្ឋកិច្ចពិភពលោកបានជួបការលំបាកជាច្រើននិងកំណើនតិចតួចមិននឹងនរស្មើរតែធ្លាក់ទៅក្នុងសភាពធូន់ធូរម្តងទៀត។ វិបត្តិបំណុលសាធារណៈនៅក្នុងតំបន់អឺរ៉ុបបានក្លាយជាបញ្ហាប្រឈម ដែលបណ្តាលឲ្យសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១១ មានកំណើនទាបជាងឆ្នាំ២០១០ ។ ទន្ទឹមនោះ បញ្ហាអតុល្យភាពសេដ្ឋកិច្ចសកលក៏ពុំទាន់មានដំណោះស្រាយសមស្រប ខណៈដែលប្រទេសអភិវឌ្ឍន៍មួយចំនួននៅមានអត្រានិកម្មភាពខ្ពស់ ជំនឿទុកចិត្តអ្នកវិនិយោគនិងអ្នកប្រើប្រាស់នៅទាបហើយការស្តារឡើងវិញពីគ្រោះធម្មជាតិក៏ពុំទាន់បានបញ្ចប់ជាស្ថាពរនៅឡើយ ។

តាមការប៉ាន់ស្មានរបស់មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) បានបង្ហាញថា កំណើនសេដ្ឋកិច្ចពិភពលោកបានថយចុះពី ៥,១% នៅឆ្នាំ២០១០ មក ៤% នៅឆ្នាំ២០១១ ក្នុងនោះ សេដ្ឋកិច្ចប្រទេសអភិវឌ្ឍន៍ ដូចជាសហរដ្ឋអាមេរិកមានអត្រាកំណើន ១,៥% និងអឺរ៉ុប ១,៦% ខណៈដែលសេដ្ឋកិច្ចតំបន់អាស៊ីមានមូលដ្ឋានរឹងមាំក្នុងការរួមចំណែកដល់កំណើនសេដ្ឋកិច្ចពិភពលោក ក្នុងនោះ ប្រទេសចិនមានអត្រាកំណើន ៩,៤% ឥណ្ឌា ៧,៨% និងអាស៊ានធំប្រាំ ៥,៣% ទោះបីសេដ្ឋកិច្ចជប៉ុនមានកំណើន -0,៥% ក៏ដោយ ។

ប្រទេសកម្ពុជាឆ្នាំ២០១១ បានបង្ហាញលទ្ធផលគួរកត់សម្គាល់ ដោយស្ថានភាពម៉ាក្រូសេដ្ឋកិច្ចរក្សាស្ថិរភាពយ៉ាងល្អប្រសើរ ទោះបីជាមានផលប៉ះពាល់ពីគ្រោះទឹកជំនន់នៅតំបន់ខ្លះក្តី ។ ស្ថិតក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងនិងការអនុវត្តនយោបាយសារពើពន្ធនិងរូបិយវត្ថុសមស្របរបស់រាជរដ្ឋាភិបាល សេដ្ឋកិច្ចកម្ពុជាត្រូវបានរំពឹងថានឹងមានកំណើនប្រមាណ ៦,៤% ដែលទ្រទ្រង់ដោយការរីកចម្រើននៃវិស័យកសិកម្ម ១,៤% ឧស្សាហកម្ម ១៤,១% (វិស័យកាត់ដេរ ២១%) និងសេវាកម្ម ៥% ។

ចំពោះវិស័យធនាគារមានការអភិវឌ្ឍជាលំដាប់ទាំងវិសាលភាពនិងទំហំប្រតិបត្តិការ ។ នៅឆ្នាំ២០១១ សាខាធនាគារបរទេសខ្នាតអន្តរជាតិចំនួន៣ បានទទួលអាជ្ញាប័ណ្ណធ្វើប្រតិបត្តិការធនាគារនៅកម្ពុជា ។ បណ្តាញសាខារបស់គ្រឹះស្ថានធនាគារបានកើនឡើងពី ៣៦១ នៅឆ្នាំ២០១០ ដល់ ៤០៧ នៅឆ្នាំ២០១១ ។ ប្រាក់បញ្ញើក្នុងប្រព័ន្ធធនាគារ និងឥណទានចំពោះវិស័យឯកជនបានកើនឡើង ២០% និង ២៨% រៀងគ្នា ធៀបឆ្នាំ២០១០ ហើយវិស័យដែលមានកំណើនឥណទានខ្ពស់ជាងគេគឺកសិកម្ម ៥៤% ឧស្សាហកម្ម៣៧% និងសំណង់ ៣៦%។

ទន្ទឹមនេះ វិស័យមីក្រូហិរញ្ញវត្ថុក៏មានការរីកចម្រើនជាលំដាប់និងមានបណ្តាញសេវាទូលំទូលាយដល់ជនបទ ។ វិស័យនេះ បានដើរតួនាទីយ៉ាងសកម្មក្នុងការរួមចំណែកអនុវត្តកម្មវិធីកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល ។ ឥណទានមីក្រូហិរញ្ញវត្ថុបានកើនដល់ ២.២៩៧ ពាន់លានរៀល មានកំណើន ៣៣% ធៀបនឹងឆ្នាំកន្លងទៅ ខណៈចំនួនអតិថិជនបានកើនដល់ជាង១លាននាក់ ។ លទ្ធផលនេះបានបង្ហាញនូវការយកចិត្តទុកដាក់នៃវិស័យធនាគារក្នុងការលើកកម្ពស់វិស័យកសិកម្មស្របតាមការចង្អុលទិសដ៏ត្រឹមត្រូវរបស់រាជរដ្ឋាភិបាល ។ គ្រឹះស្ថានធនាគារមានសុខភាពរឹងមាំ ដែលឆ្លុះបញ្ចាំងដោយអនុបាតសាធនភាពជាមធ្យមក្នុងកម្រិតប្រមាណ ២៨,៦% អនុបាតសាច់ប្រាក់ងាយស្រួល (សន្ទនីយភាព) ៨៧% និងអនុបាតឥណទានមិនដំណើរការ ៣,៣% ។

ក្នុងនាមជាអាជ្ញាធររូបិយវត្ថុជាតិ ធនាគារជាតិនៃកម្ពុជាបានខិតខំរក្សាស្ថិរភាពថ្លៃ ស្ថិរភាពអត្រាប្តូរប្រាក់តាមរយៈការអនុវត្តគោលនយោបាយរូបិយវត្ថុប្រុងប្រយ័ត្នសំដៅរួមចំណែកពង្រឹងស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងទ្រទ្រង់ស្ថិរភាពប្រព័ន្ធហិរញ្ញវត្ថុ ។ សម្ពាធអតិផរណាក្នុងឆ្នាំ២០១១ ស្ថិតក្នុងកម្រិតដែលអាចគ្រប់គ្រងបានដោយមានអត្រាមធ្យមប្រចាំឆ្នាំត្រឹម ៥,៥% ខណៈនោះដែរ ប្រាក់រៀលបានឡើងថ្លៃ ៣,៧% ធៀបនឹងឆ្នាំមុន ដែលបណ្តាលមកពីការកើនឡើងនៃតម្រូវការប្រាក់រៀលក្នុងសកម្មភាពសេដ្ឋកិច្ច ។ ជារួមក្នុងអំឡុងមួយទសវត្សរ៍នេះ អត្រាប្តូរប្រាក់រៀលធៀបនឹងប្រាក់ដុល្លារអាមេរិកមានស្ថិរភាពល្អប្រសើរ ដែលបានរួមចំណែកពង្រឹងជំនឿទុកចិត្តរបស់សាធារណជនលើប្រព័ន្ធធនាគារ ។ ធនាគារជាតិនៃកម្ពុជាបានបន្តពង្រឹងនិងអភិវឌ្ឍប្រព័ន្ធធនាគារយ៉ាងយកចិត្តទុកដាក់សំដៅជំរុញប្រតិបត្តិការធនាគារឲ្យប្រព្រឹត្តទៅដោយរលូនមានប្រសិទ្ធភាពនិងសុវត្ថិភាពតាមរយៈការលើកកម្ពស់ការត្រួតពិនិត្យនិងការរៀបចំក្របខ័ណ្ឌបទប្បញ្ញត្តិនានា ។ ក្នុងក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការតំបន់និងអន្តរជាតិ ធនាគារជាតិនៃកម្ពុជាបានធ្វើជាម្ចាស់ផ្ទះរៀបចំកិច្ចប្រជុំលើកទី៤ ថ្នាក់ទេសាភិបាលរងអាស៊ានផ្នែកសមាហរណកម្មវិស័យហិរញ្ញវត្ថុ កិច្ចប្រជុំប្រចាំឆ្នាំថ្នាក់នាយកប្រតិបត្តិស៊ាសិនលើកទី៩ និងកិច្ចប្រជុំថ្នាក់ទេសាភិបាលធនាគារកណ្តាលនៃក្រុមប្រទេសនិយាយភាសាបារាំង (ហ្វ្រង់កូហ្វូន) លើកទី១៨ ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងមន្ត្រីបុគ្គលិកគ្រប់ជាន់ថ្នាក់ ព្រមទាំងក្រសួងស្ថាប័ន និងដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលបានចូលរួមវិភាគទាននិងសហការយ៉ាងជិតស្និទ្ធជាមួយធនាគារជាតិនៃកម្ពុជាក្នុងការសម្រេចបាននូវភារកិច្ចជាបន្តបន្ទាប់ ។

ខ្ញុំសូមប្រសិទ្ធពរជ័យ សិរីសួស្តី ជូនដល់ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តអ្នកអានទាំងអស់ សូមប្រកបតែសេចក្តីសុខ ទទួលបានជោគជ័យគ្រប់ភារកិច្ចនិងជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ!**

## មាតិកា ទំព័រ


- អារម្ភកថា ........................................ i-ii
- សុន្ទរកថា ឯកឧត្តម ជា ចាន់តូ ទេសាភិបាលធនាគារជាតិ នៃកម្ពុជា ថ្លែងក្នុងពិធីសម្ពោធស្ពានត្រពាំងត្រុំ និងដាំកូនឈើនៅភូមិទីពោ ស្រុកសន្ទុក.................. ១
- ប្រកាស ស្តីពីការចែករំលែកព័ត៌មានឥណទាន........................................ ១១
- ទស្សនវិស័យសេដ្ឋកិច្ចសកលទស្សនវិស័យវិជ្ជមានរបស់សេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ២០១២ - ២០១៣........................................ ៤៣
- តារាងអត្រាប្តូរប្រាក់ប្រចាំខែ ........................................ ៥០
- តារាងអត្រាការប្រាក់លើប្រាក់បញ្ញើ ........................................ ៥១
- តារាងអត្រាការប្រាក់លើប្រាក់កម្ចី ........................................ ៥៣
- បញ្ជីឈ្មោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ........................................ ៥៥
- បញ្ជីឈ្មោះមីក្រូហិរញ្ញវត្ថុបានចុះបញ្ជីនៅធនាគារជាតិនៃកម្ពុជា........................ ៨០
.
- ប្រព័ន្ធធនាគារកម្ពុជា ........................................ ៨២
- រូបថតសកម្មភាពថ្នាក់ដឹកនាំធនាគារជាតិ នៃ កម្ពុជា........................................ ៨៤-១០១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ធនាគារជាតិ នៃ កម្ពុជា

លេខ..........................................................

# សុន្ទរកថា
# ឯកឧត្តម អគ្គទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ថ្លែងក្នុងពិធីសម្ពោធស្ពានត្រពាំងត្រុំ និងដាំកូនឈើនៅភូមិទីពោ ស្រុកសន្ទុក
# កំពង់ធំ ថ្ងៃទី១ ខែមិថុនា ឆ្នាំ២០១១

ជាបឋម ខ្ញុំព្រះករុណាខ្ញុំ សូមក្រាបថ្វាយបង្គំព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
ខ្ញុំសូមគោរព ៖

- ឯកឧត្តម Jang Ho Jin ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េ ប្រចាំនៅកម្ពុជា
- ឯកឧត្តម ណាំ ទុំ ទីប្រឹក្សាសម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងជាប្រធានក្រុមប្រឹក្សាខេត្តកំពង់ធំ
- ឯកឧត្តម ឈុន ឈន់ អភិបាលនៃគណៈអភិបាលខេត្តកំពង់ធំ
- លោក Lee Joon Ho ប្រធានក្រុមហ៊ុន BNA
- លោក Back Byung Kun អគ្គនាយកក្រុមហ៊ុន BNA
- ឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រីរាជការក្រុមប្រឹក្សាស្រុក-ឃុំ លោកគ្រូ អ្នកគ្រូ មិត្តភក្តិអន្តរជាតិ និងបងប្អូនប្រជាពលរដ្ឋទាំងអស់ ជាទីស្នេហា!

ថ្ងៃនេះ ខ្ញុំព្រះករុណាខ្ញុំ មានសេចក្ដីសោមនស្សរីករាយជាអនេក ដោយបានមកជួបជាមួយឯកឧត្តម លោកជំទាវ លោក លោកស្រី ជាមន្ត្រីរាជការក្រុមប្រឹក្សាស្រុក-ឃុំ លោកគ្រូ អ្នកគ្រូ ពូមីង និងបងប្អូនប្រជាពលរដ្ឋទាំងអស់ នៅក្នុងពិធីសម្ពោធស្ពានត្រពាំងត្រុំនិងដាំកូនឈើ នៅឃុំទីពោ ស្រុកសន្ទុក ស្របពេលដែលបងប្អូនប្រជាពលរដ្ឋកម្ពុជាយើងទូទាំងប្រទេស កំពុងប្រារព្ធធ្វើទិវាកុមារអន្តរជាតិនិងទិវាកុមារកម្ពុជាផងដែរ ។ ខ្ញុំព្រះករុណាខ្ញុំ សូមអរគុណានិងឯកភាពតាមមតិរបស់ឯកឧត្តម ឯកអគ្គរដ្ឋទូតសាធារណរដ្ឋកូរ៉េប្រចាំនៅកម្ពុជា និងរបាយការណ៍របស់លោកអភិបាលស្រុកសន្ទុកដែលបានលើកឡើង ។ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះមតិនេះ ហើយនេះគឺជាសមិទ្ធផលថ្មីមួយបន្ថែមទៀត ជាចំណងដៃសម្រាប់បងប្អូនប្រជាជនយើងនៅស្រុកសន្ទុក ជាពិសេសនៅឃុំទីពោ ទុកសម្រាប់ប្រើប្រាស់ជាសាធារណៈ ។

ខ្ញុំព្រះករុណាខ្ញុំ សូមយកឱកាសនេះថ្លែងការកោតសរសើរយ៉ាងខ្លាំង និងអរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមហ៊ុនគូរ៉េ ដែលបានរួមចំណែកកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្តសង្គម ជាពិសេសថ្លែងអំណរគុណចំពោះលោក Lee Joon Ho ប្រធានក្រុមហ៊ុន BNA លោក Back Byung Kun អគ្គនាយកក្រុមហ៊ុន BNA និងសប្បុរសជនដទៃទៀត ដែលបានខិតខំប្រឹងប្រែងកសាងស្ពានត្រពាំងត្រុំនេះឡើងវិញ មានបណ្ដោយ ១៦ម៉ែត្រ និងមានទទឹង ៦ម៉ែត្រ ធ្វើពីបេតុងអាម៉េ និងចូលរួមដាំកូនឈើលើផ្ទៃដីប្រមាណ ៦ហិចតា នៅក្នុងឃុំទីពោនេះ ទុកជាសម្បត្តិរដ្ឋជូនបងប្អូនប្រជាពលរដ្ឋទាំងអស់នៅក្នុងស្រុកសន្ទុក ជាពិសេស សម្រាប់ក្មួយៗយុវជនជំនាន់ក្រោយរស់ក្នុងភូមិឃុំគំរូ ដែលមានបរិស្ថានស្អាតបរិសុទ្ធបែបធម្មជាតិតរៀងទៅ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ជាទីស្នេហា

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំព្រះករុណាខ្ញុំ សូមអនុញ្ញាតលើកយកប្រសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់ **សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថា ការកសាងផ្លូវ-ស្ពាន-ដាំកូនឈើ គឺជាការងារដែលមានចរិតយុទ្ធសាស្ត្រសំខាន់ណាស់ ក្នុងការអនុវត្តគោលនយោបាយសន្តិភាវូបនីយកម្ម និងសមាហរណកម្មក្នុងប្រទេស គោលនយោបាយជំរុញលើកកម្ពស់កំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។ តាមរយៈការកសាងផ្លូវ-ស្ពាន-ដាំកូនឈើនៅពេលនេះ ប្រជាជនកម្ពុជាយើងទទួលបានអត្ថប្រយោជន៍ច្រើនណាស់ ក្នុងការធ្វើដំណើរការដឹកជញ្ជូនសាធារណៈ ពាណិជ្ជកម្មធំៗ ការប្រកបមុខរបរចិញ្ចឹមជីវិតនិងប្រាក់ចំណូល ។

ការកសាងផ្លូវ-ស្ពានក្នុងដួងព្រលឹងវប្បធម៌និងប្រពៃណីខ្មែរយើង មានអត្ថន័យសំខាន់ជ្រាលជ្រៅ និងមានតម្លៃខ្លាំងណាស់ ទាំងផ្នែកពុទ្ធចក្រនិងផ្នែកអាណាចក្រ ។ ដូចពាក្យចាស់បុរាណបានអប់រំផ្នែកសីលធម៌ចំពោះប្រជាជនខ្មែរយើង ដែលនិយាយថា " មានផ្លូវមានសង្ឃឹម មានផ្លូវមានលទ្ធភាព មានផ្លូវមានឱកាស " ដូច្នេះ យើងត្រូវឆ្លៀតប្រើឱកាសនេះធ្វើអ្វីមួយដើម្បីបានជាគុណប្រយោជន៍សម្រាប់ខ្លួនឯងនិងអ្នកដទៃ ។ ផ្ទុយទៅវិញ ចំពោះអ្នកបោកប្រាស់វិញ យើងតែងនិយាយថា " ធ្វើអញ្ចឹងគឺលក់ផ្លូវហើយ " នេះមានន័យថា បើបុគ្គលនោះធ្វើអំពើមិនល្អ គឺបាត់បង់ឱកាស បាត់បង់លទ្ធភាព និងបាត់បង់ក្ដីសង្ឃឹមក្នុងជីវិតនិងការងារហើយ ។

ផ្នែកពុទ្ធចក្រ : ផ្លូវ-ស្ពាន គឺជាយានចម្លងពីកន្លែងមួយទៅកន្លែងមួយទៀត ឬពីឋានមនុស្សលោកទៅឋានទេវតា ។ ជាក់ស្ដែង នៅតាមប្រាសាទបុរាណខ្មែរ យើងតែងសង្កេតឃើញមានស្ពាននាគជានិច្ច ទោះជាមានទឹក ឬគ្មានទឹកក៏ដោយ ជាពិសេសនៅប្រាសាទអង្គរវត្ត មានស្ពាននាគភ្ជាប់ពីច្រកចូលទៅតួប្រាសាទ មានន័យថា ជាផ្លូវឬស្ពានចម្លងពីឋានមនុស្សលោកទៅឋានសួគ៌ ដែលជាកន្លែងឱ្យយើងសម្រេចផលសោយសុខ ។ ព្រះពុទ្ធបានមានពុទ្ធដីកាថា អ្នកណាដែលមានសទ្ធា

ជ្រះថ្លាបានសាងផ្លូវ-ស្ពាន នឹងទទួលបានផលានិសង្សច្រើនណាស់ សម្រាប់ជាតិនេះនិងទៅជាតិក្រោយ ព្រោះអ្នកធ្វើដំណើរតាមផ្លូវ-ស្ពានតែងតែនឹកដល់ ជូនពរ និងថ្លែងអំណរគុណចំពោះអ្នកសាងសង់ជានិច្ច ។

ចំពោះផ្នែកអាណាចក្រវិញ ស្ពាន តាមន័យត្រង់ មានន័យថា ជាសំណង់ដែលឆ្លងកាត់ទទឹងលើផ្លូវទឹក ។ បើតាមន័យធៀបវិញ ស្ពានមានន័យថា ជាចំណងមេត្រីភាព ឬចងស្ពានមេត្រីភាពជាការសហប្រតិបត្តិការគ្នា ឬការស្រឡាញ់រាប់អានគ្នា ជាកិច្ចសហប្រតិបត្តិការបរទេសជាមួយប្រទេសនៅក្នុងតំបន់និងពិភពលោក ។ តាមអត្ថន័យបទចម្រៀងរបស់លោក ស៊ិន ស៊ីសាមុត បានពោលថា " ឱលោកយាយទេពនៅអែបផ្សារក្រោម ចៃចូវល្អងលោមរូបស្រីឱ្យបាន មានតែយាយទេជាផ្លូវជាស្ពាន កាលណាខ្ញុំបាន ខ្ញុំថ្វាយភ្លេងការ "។

នេះគឺជាអត្ថន័យស្ពានក្នុងដួងព្រលឹងវប្បធម៌ខ្មែរយើង គឺមានអត្ថន័យសំខាន់ណាស់ទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងវប្បធម៌សង្គម ។ ផ្នែកសេដ្ឋកិច្ចសង្គម ផ្លូវ-ស្ពាន គឺមានន័យថា បងប្អូនប្រជាពលរដ្ឋយើងអាចដឹកជញ្ជូនកសិផលទៅលក់នៅទីផ្សារ និងទិញគ្រឿងឧបភោគបរិភោគ-បរិក្ខារពីទីផ្សារមកប្រើប្រាស់ប្រចាំថ្ងៃ ដូចជា ការងារផលិតកម្មអាចស្វែងរកឥណទានពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ សេវាសុខាភិបាល ប្រភពទឹកស្អាត សេវាអប់រំ ទេសចរណ៍ និងសេវាផ្សេងៗសម្រាប់ខ្លួន កូនចៅ និងក្រុមគ្រួសាររបស់ខ្លួន ។

ជាមួយគ្នានេះ ស្ពាននេះក៏មានអត្ថន័យជ្រាលជ្រៅក្នុងការផ្សារភ្ជាប់ និងការរឹតចំណងយ៉ាងជិតស្និទ្ធ នូវទំនាក់ទំនងរវាងប្រទេសកម្ពុជាជាមួយប្រទេសកូរ៉េ និងរវាងប្រជាជនកម្ពុជានិងប្រជាជនកូរ៉េ ដែលជាការរួមចំណែកលើការអភិវឌ្ឍសេដ្ឋកិច្ចសង្គម និងសម្រួលដល់ការថែរក្សាសន្តិភាពស្ថិរភាពនយោបាយនៅក្នុងតំបន់ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនកម្ពុជាផងដែរ ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ជាទីស្នេហា

ការកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ខ្វាត់ខ្វែងដល់តំបន់ជនបទ គឺជាទិសដៅអាទិភាពរបស់រដ្ឋាភិបាលកម្ពុជា ដើម្បីបម្រើឱ្យបានសមស្របតាមសេចក្តីត្រូវការនៃជីវភាពប្រចាំថ្ងៃរបស់ប្រជាជន និងសេចក្តីត្រូវការនៃសេដ្ឋកិច្ចជាតិនៅក្នុងការដឹកជញ្ជូន ការជំរុញវិស័យពាណិជ្ជកម្មវិនិយោគ និងទេសចរណ៍ និងការធ្វើសមាហរណកម្មតំបន់ដាច់ស្រយាលនៃប្រទេសកម្ពុជា ឱ្យផ្សារភ្ជាប់គ្នាយ៉ាងពេញលេញ ហើយប្រែក្លាយទៅជាតួអង្គសេដ្ឋកិច្ចមួយដែលមានជវភាព មានច្រកទាក់ទងប្រកបដោយប្រសិទ្ធភាព ជាមួយនឹងចរន្តសេដ្ឋកិច្ចអន្តរជាតិ ដើម្បីបម្រើគោលដៅនៃការអភិវឌ្ឍនិងកាត់បន្ថយភាពក្រីក្រ ។

សារៈសំខាន់ខាងសេដ្ឋកិច្ចនៃផ្លូវ-ស្ពាននេះ នៅពេលសាងសង់គ្រាដំបូង បានធ្វើឱ្យប្រជា-ពលរដ្ឋនៅស្រុកសន្ទុកទាំងមូល ពិសេសបណ្ដាឃុំទាំងឡាយនៅក្បែរឃុំទីពោ អាចធ្វើដំណើរឆ្លងកាត់ និងដឹកនាំកសិផលយកទៅលក់នៅទីផ្សារបានដោយស្រួល ។ ក្រៅពីនេះ ក្មួយៗកុមារា-កុមារីដែលជាសិស្សានុសិស្ស ក៏បានធ្វើដំណើរទៅសាលារៀន ហើយភ្ញៀវទេសចរជាតិនិងអន្តរជាតិក៏អាចមកទស្សនាបានដោយស្រួល នៅពេលថ្ងៃបុណ្យទាន ។

ប្រទេសកម្ពុជាបច្ចុប្បន្ន មានសន្តិភាពពេញលេញ យើងត្រូវចេះផ្ដុំកម្លាំងគ្នាបន្ថែមទៀតដើម្បីការអភិវឌ្ឍនិងកសាងប្រទេសជាតិឱ្យសម្បូរសប្បាយរុងរឿង ។ ការអភិវឌ្ឍនឹងផ្ដល់នូវសេចក្ដីថ្លៃថ្នូរ និងក្ដីសង្ឃឹមចំពោះអនាគតដ៏ភ្លឺស្វាងដល់ជាតិរបស់យើង ។ ទីក្រុងស្អាត ជនបទគំរូគឺជាមោទនភាពដ៏ខ្ពង់ខ្ពស់របស់យើង ហើយការចូលរួមផ្ទាល់របស់សហគមន៍មូលដ្ឋាននៅក្នុងការអភិវឌ្ឍ គឺជាកម្លាំងឈានមុខរបស់យើងផងដែរ ។ មានតែសហគមន៍មូលដ្ឋានទេដែលដឹងច្បាស់អំពីតម្រូវការជាក់ស្ដែងរបស់ខ្លួននៅក្នុងការអភិវឌ្ឍ ។ ផ្អែកលើមូលដ្ឋាននៃទស្សនវិជ្ជានេះហើយទើបរាជរដ្ឋាភិបាលបានដាក់ចេញនិងអនុវត្តយ៉ាងស្វាហាប់ នូវគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ ។

បច្ចុប្បន្នយើងមានក្រុមប្រឹក្សាឃុំ-សង្កាត់ទាំងអស់ គឺសុទ្ធសឹងតែជាតំណាងដែលបានមកពីការជ្រើសរើសដោយផ្ទាល់របស់បងប្អូនប្រជាជនយើង តាមរយៈការបោះឆ្នោតដោយសម្ងាត់ដោយសេរី និងយុត្តិធម៌ ។ ពួកគេទាំងអស់គ្នាត្រូវមានភារកិច្ចដឹកនាំ និងចូលរួមដោយផ្ទាល់ជាមួយអ៊ំ ពូមីង និងបងប្អូនយើងក្នុងការអភិវឌ្ឍភូមិ-ឃុំ ក្នុងទិសដៅកាត់បន្ថយភាពក្រីក្រ លើកកម្ពស់ជីវភាពរស់នៅ និងសុខមាលភាពរបស់បងប្អូនប្រជាពលរដ្ឋយើងទាំងអស់គ្នា ។

ការវិនិយោគប្រកបដោយលទ្ធផលជាផ្លែផ្កា គឺដោយសារការអនុវត្តភាពជាដៃគូរវាងរដ្ឋនិងឯកជន ហើយជាគំរូដ៏សំខាន់មួយនៃការចូលរួមចំណែករបស់ក្រុមហ៊ុនឯកជនក្នុងស្រុក ក្នុងការជួយកសាងនិងអភិវឌ្ឍប្រទេសជាតិ និយាយជារួម និងក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធ និយាយដោយឡែក ស្របពេលដែលរាជរដ្ឋាភិបាលកំពុងតែខិតខំជំរុញយ៉ាងខ្លាំងក្លា ក្នុងការកែទម្រង់លើគ្រប់វិស័យ និងការធ្វើសមាហរណកម្មសេដ្ឋកិច្ចនិងសង្គមទៅក្នុងពិភពលោកនិងក្នុងតំបន់ ដើម្បីអភិវឌ្ឍប្រទេសឱ្យបានរីកចម្រើនជឿនលឿន ដូចប្រទេសអភិវឌ្ឍនានាលើសកលលោក ។

ដូចនេះ ខ្ញុំព្រះករុណាខ្ញុំ សូមឱ្យបងប្អូនទាំងអស់មេត្តាផ្ដល់ការយកចិត្តទុកដាក់ និងសស្រាក់សស្រាំ ព្រួតដៃគ្នាជួយពង្រឹងការងារសហគមន៍ ហើយចូលរួមឱ្យបានសកម្មបំផុតនៅក្នុងការអភិវឌ្ឍនិងការថែរក្សាសមិទ្ធផលទាំងឡាយរបស់ជាតិ ដូចជា ផ្លូវ ស្ពាន មន្ទីរពេទ្យ សាលារៀនជាដើម ឱ្យបានគង់វង្ស និងប្រើប្រាស់បានយូរអង្វែងរាប់ជំនាន់តរៀងទៅ ។ ក្នុងរយៈពេលពីរ-បីឆ្នាំចុងក្រោយនេះ តាមរយៈយុទ្ធសាស្ត្រ " **ក្បាលរថភ្លើង** " ដែលកំណត់យកការកសាងហេដ្ឋា-

រចនាសម្ព័ន្ធរូបវន្ត ពិសេស ថ្នល់ ស្ពានជាកម្លាំងអូសទាញឱ្យសេដ្ឋកិច្ចជាតិស្ទុះងើបឡើង និងជាចលករសម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព រាជរដ្ឋាភិបាលបានធ្វើការសាងសង់និងជួសជុលឡើងវិញនូវបណ្តាគមនាគមន៍ ផ្លូវ-ស្ពានជាច្រើន ។

ព្រះថេរានុថេរៈគ្រប់ព្រះអង្គ ជាទីសក្ការៈ
ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនប្រជាពលរដ្ឋ ជាទីស្នេហា

មុននឹងបញ្ចប់ ជាថ្មីម្តងទៀត ខ្ញុំព្រះករុណាខ្ញុំ ក៏សូមអំពាវនាវឱ្យស្ថាប័នមានសមត្ថកិច្ចអាជ្ញាធរដែនដី និងបងប្អូនប្រជាពលរដ្ឋទាំងអស់ សូមមេត្តាសហការនិងគាំទ្រដល់ការប្រឹងប្រែងក្នុងការស្តារនិងកសាងហេដ្ឋារចនាសម្ព័ន្ធផ្លូវ-ស្ពាន ហើយជាពិសេស សូមបងប្អូនមេត្តាជួយថែទាំហេដ្ឋារចនាសម្ព័ន្ធផ្លូវ-ស្ពានទាំងអស់នេះឱ្យបានគង់វង្ស ប្រយោជន៍ប្រើប្រាស់សមិទ្ធផលទាំងនេះឱ្យបានយូរអង្វែងតរៀងទៅ ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរជ័យព្រះថេរានុថេរៈគ្រប់ព្រះអង្គ សូមមានព្រះសុខភាពល្អ និងមានព្រះជន្មាយុយឺនយូរ ។ ខ្ញុំព្រះករុណាខ្ញុំ ក៏សូមថ្លែងអំណរគុណនិងជូនពរចំពោះមិត្តភ្ញៀវ និងសប្បុរសជនដទៃទៀត ដែលបានចូលរួមចំណែកដល់កិច្ចដំណើរការនៃការអភិវឌ្ឍគ្រប់បែបយ៉ាងនៅកម្ពុជា សូម ឯកឧត្តម លោកជំទាវ និងសហការី មានសុខភាពល្អ កម្លាំងមាំមួន និងទទួលបានជ័យជម្នះគ្រប់ភារកិច្ចជានិច្ច ។ សូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងបងប្អូនប្រជាជនទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**ខ្ញុំសូមប្រកាសបើកឱ្យដំណើរការស្ពានត្រពាំងត្រុំ និងចាប់ផ្តើមពិធីដាំកូនឈើ ចាប់ពីពេលនេះតទៅ។**

**សូមអរគុណ!**

KINGDOM OF CAMBODIA
NATION RELIGION KING

NATIONAL BANK OF CAMBODIA

# Remarks

## By

## His Excellency Chea Chanto, Governor of the National Bank of Cambodia On the Occasion of Tra Paing Trom Bridge Inauguration and Tree Plantation Ceremony in Tipo Commune, Santuk District Kompong Thom, 01 June 2011

First of all, let me pay my due respect to:

- Venerable Buddhist Monks
- His Excellency Jang Ho Jin, Ambassador of the Republic of Korea to Cambodia
- His Excellency Nam Tum, Advisor to Samdech Akkak Moha Sena Padei Decho Hun Sen, Prime Ministrer of the Kingdom of Cambodia, and Chairman of Kompong Thom Province Council
- His Excellency Chhun Chhuon, Governor of Kompong Thom Province
- Mr. Lee Joon Ho, Chairman of BNA
- Mr. Back Myung Kun, Director General of BNA
- Excellencies, Ladies and Gentlemen!

Today I have a great pleasure to personally meet Your Excellencies, Ladies and Gentlemen, the district and communal council's members, civil servants, teachers and all the people from various communes in Santuk distric at the inauguration of Tra Paing Trom Bridge and Tree Plantation Ceremony in Tipo Commune, Santuk District. Our ceremony today is celebrated coinciding with the time when Cambodian people all over the country are celebrating International and National Children's Day. I do agree with the remarks of His Excellency Ambassador and the report of Santuk district governor raising.

I appreciate those very much. This is additionally new achievements provided by Korean friends for our people in Santuk District especially those living in Tipo Commune.

Taking this opportunity, I would like to praise and express my deepest gratitude to our Korean friends for contributing to Cambodia's social psysical infrastructure development, especially Mr. Lee Joon Ho, Chairman of BNA, Mr. Back Byung Kun, Director General of BNA and other generous contributors for putting efforts to rebuilding the Tra Paing Trom Bridge, which has 16 meters long and 6 meters wide and planting trees in the area of 6 hectars of land and keeping as the state's properties and for the people living in Santuk district, especially, for our younger generation to live in a naturally clean and pure environment.

- Venerable Buddhist Monks
- Excellencies, Ladies and Gentlemen!

Please allow me to recall the valuable recommendations of Samdech Akkak Moha Sena Padei Decho Hun Sen, Prime Minister of the Kingdom of Cambodia, that construction of road-bridge and tree plantations are categorized as a very important strategy to implement peacefulization policy, internal integration, generating sustainable economic growth and poverty reduction in Cambodia. Construction of road-bridge and tree plantation provide enormous economic benefits to our people in terms of traveling, public transportation, trade and income generating.

In Khmer traditional culture the construction of road-bridge is very important and valuable in our soul in terms of buddhism and profane power. According to Khmer old saying, "when we have a way, it means that we have hope, ability and opportunity". Therefore, we have to take such opportunity to do something beneficial to others and ourselves. In contrary, our people always say to the cheator that "if you are cheating, you are trying to destroy your way".

For Buddhism power: road-bridge is a vehicle to transport people from one place to another, from earth to paradise. Having seen the fact of every Khmer temple, we always note that there are dragon bridges with water underneath. At Angkor Wat temple we see dragon bridge connecting the main entrance of the temple to the gate; this means that it is a transitory bridge that connects human world to paradise, a place for us to achieve good deeds and live in happiness. The buddha says those who are generous to build road- bridge will receive good deeds in this live and next lives because people who travel on the road and cross the bridge will always praise and thank the builders.

For profane power: bridge is directly defined as a piece of construction that lies across a water way. Bridge can politically and diplomatically be defined as strengthening friendship or loving. Let me extract Mr. Ṡin Sisamut′s song: A man wants to love a beautiful girl. He asked a lady god to be a bridge to help consol her to accept his love. He promise to entertain the lady god with wedding music if the beautiful lady accepts his love and marry him.

This is the meaning of bridge embeded in Khmer culture. It has very important meaning in terms of politic, econmic and social culture. In the field of social economy, having road-bridge will allow our people to bring their agricultural product to the market and buy stuff from the market to support their daily lives and have easier access to 1) credits from banks and financial institutions, 2) health services, 3) clean water resources, and 4) training and education services for themselves and for their families.

In the same vein, this bridge has a deep meaning in tightening close relationship between Cambodia and Korea and between Cambodian people and Korean people. It will contribute to social economic development and facilitate peace and political stability in the region and reduce poverty in Cambodia.

- Venerable Buddisht Monks
- Excellencies, Ladies and Gentlemen!

Building road-bridge infrastructure in rural areas is a priority target of the Royal Government of Cambodia to meet demand of people's daily live and the economy that need road-bridge to facilitate transportation, trade promotion, investment and tourism, fully integrate remote areas within the country, and transform them to economic structures that accelerate the economic growth and provide efficient connection with international economies and meet the development and poverty reduction goals.

The economic importance of bridge is to serve people in Santuk province, especially communes near Ti Po commune to transport easily the agricultural products to markets. Beside, Schoolchildren could easily reach schools and national and international tourists could come and visit. I do believe beside this importance this bridge would facilitate works and every day's life of our people here in numerous ways. This is clear evidence that the construction of infrastructure roads-bridges in the context of full peace is an important strategy and is very needed for a sustainable economic growth and a strong national integrity and prosperity.

Cambodia gains today full peace; we should further reunite our force for development and national rehabilitation. The development would provide dignity and hopes in a bright future for our nation. A clean city and model rural areas are our high pride. The direct participation of the base community in the development is our prior force. Only base community understands their own real needs well in the development. Based on this psychology the Royal Government of Cambodia sets out and firmly implements decentralized and co-decentralized policy.

Today we have all commune and district councils and they are all representatives selected by our citizens through the secret ballots and free and fair election. They all have duties to lead and directly participate with our citizen in the development of commune, aiming at reducing poverty, raising standard of living and bringing happiness to our citizens.

Fruitful investments depend on good partnerships between the Government and the private sector. It is an important model of the participation of private companies in the

country in rehabilitating and developing the country in general, and in rehabilitating infrastructures in particular, while the Government is trying to strongly promote the reforms in all sectors and integrate society and economy to the world and the region, so as to develop the country to reach the level of developed countries in the world.

Thus, I would like you all to have confidence in and dynamically cooperate with the community to strengthen their duties and actively participate in the development and maintaining the achievements of the Nation, such as roads, bridges, hospitals, schools, etc... During the last two-three years, due to the "Engine" strategy, which determines the rehabilitation of physical infrastructure especially road-bridge as forces to stimulate growth and sustainable development, the Government has built and rehabilitated the numerous telecommunication networks such as road-bridge.

- Venerable Buddhist Monks
- Excellencies, Ladies and Gentlemen

Before ending, I would like to call on all mandatory entities, local authorities and individual citizen to cooperate and support the efforts to build and rehabilitate infrastructure, roads and bridges, and especially help maintain these roads and bridges and use these achievements in a sustainable manner.

Finally, I would like to wish all Venerable Buddhist Monks health and longevity. I would also like to thank and wish our Korean friends and other generous contributors who have contributed to all development in Cambodia, healthy, strength and success in all endeavors. I wish Excellencies, Ladies and Gentlemen, the four Buddhist wishes: longevity, colorfulness, health and strength.

I announce the opening operation of Tra Paing Trom bridge and begin the tree plantation ceremony from now on.

Thank you!

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ ធ៧-០១១-១៤៥ ប្រ.ក

# ប្រកាស
# ស្តីពី
# ការចែករំលែកព័ត៌មានឥណទាន

.................

## ទេសាភិបាល ធនាគារជាតិនៃកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែមករា ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៦ ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០០៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា១៤ និងមាត្រា៥៧នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១៣ ចុះថ្ងៃទី១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥០៨/៥២៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ស្តីពីការតែងតាំង **ឯកឧត្តម ជា ចាន់តូ** ជាអគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា មានឋានៈស្មើទេសរដ្ឋមន្ត្រី
- យោងតាមសំណើរបស់អគ្គនាយកដ្ឋានត្រួតពិនិត្យ
- យោងតាមស្មារតីនៃអង្គប្រជុំថ្នាក់ដឹកនាំធនាគារជាតិនៃកម្ពុជា ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១. គោលបំណង

ប្រកាសនេះ មានគោលបំណងបង្កើតក្របខ័ណ្ឌសមស្របសម្រាប់ការចែករំលែកព័ត៌មានឥណទាននៅកម្ពុជា ដើម្បីលើកកម្ពស់ការផ្តល់ឥណទានប្រកបដោយ ការជឿទុកចិត្ត ការប្រកួតប្រជែង ការទទួលខុសត្រូវ និងប្រសិទ្ធភាពខ្ពស់។

## ប្រការ ២. និយមន័យ

- **សកម្មភាពមិនអំណោយផល** សំដៅដល់ការបដិសេធឥណទាន ឬការកែប្រែលក្ខខណ្ឌឥណទាន ឬកម្ចី ដោយផ្អែកលើព័ត៌មាន នៅក្នុងរបាយការណ៍ឥណទាន ។
- **អ្នកប្រើប្រាស់ប្រតិស្រុតិ** (Authorized user) សំដៅដល់បុគ្គលទាំងឡាយណាដែលទទួលបានការអនុញ្ញាតឲ្យមានសិទ្ធិបញ្ចូលនិងទាញយកទិន្នន័យពីជាតាបេស្ស (Database) ។ អ្នកប្រើប្រាស់ប្រតិស្រុតិ រួមមាន និយោជិតដែលចាត់តាំងដោយអ្នកផ្តល់ទិន្នន័យ និយោជិតរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងមន្ត្រី-បុគ្គលិកដែលបានចាត់តាំងដោយធនាគារជាតិនៃកម្ពុជា ។
- **ថ្ងៃធ្វើការ** សំដៅដល់ថ្ងៃដែលគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅប្រទេសកម្ពុជាធ្វើប្រតិបត្តិការអាជីវកម្ម ។
- **ក្រមប្រតិបត្តិ** សំដៅដល់វិធាន និងបទបញ្ញាសម្រាប់គ្រប់គ្រងប្រតិបត្តិការនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានតាមការព្រមព្រៀងរវាងធនាគារជាតិនៃកម្ពុជា និងអ្នកប្រើប្រាស់ប្រតិស្រុតិ ។
- **កាលបរិច្ឆេទចាប់ផ្តើម** សំដៅដល់ថ្ងៃដែលប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ចាប់ផ្តើមធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទានដល់អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ប្រតិស្រុតិរបស់ខ្លួន ។
- **ការយល់ព្រម** សំដៅដល់ការអនុញ្ញាតដោយស្ម័គ្រចិត្ត និងជាលាយលក្ខណ៍អក្សរដែលចុះហត្ថលេខាដោយអតិថិជនដើម្បីអនុញ្ញាតឲ្យអ្នកផ្តល់ទិន្នន័យ បញ្ចូលព័ត៌មានរបស់ខ្លួន ទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងចែករំលែកជាមួយអ្នកប្រើប្រាស់ប្រតិស្រុតិ ក្នុងគោលបំណងប្រើប្រាស់ដូចមានចែងក្នុងប្រកាសនេះ។
- **អតិថិជន** សំដៅដល់នីតិបុគ្គល ឬរូបវន្តបុគ្គលដែលទិន្នន័យរបស់ខ្លួនត្រូវបាន ឬអាចត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ទោះក្នុងទំនាក់ទំនងជាកិច្ចសន្យាជាមួយនឹងអ្នកឲ្យខ្ចី ឬពាក្យសុំខ្ចីប្រាក់ដែលចុះហត្ថលេខាដោយអតិថិជន ឬក្នុងគោលបំណងស្របច្បាប់ណាមួយផ្សេងទៀត។
- **គ្រឹះស្ថានចំណុះច្បាប់** សំដៅដល់គ្រឹះស្ថាន ដូចមានចែងនៅក្នុងច្បាប់ស្តីពីគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងទៀត ដែលទទួលបានការអនុញ្ញាតពីធនាគារជាតិនៃកម្ពុជា ។
- **ព័ត៌មានឥណទាន** សំដៅដល់ព័ត៌មានទាក់ទងនឹងកាតព្វកិច្ចខាងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់អតិថិជន រួមទាំងសាវតាទូទាត់សងប្រាក់ ការធានាព័ត៌មានដែលអាចប្រើប្រាស់បានជាសាធារណៈ និងទិន្នន័យពាក់ព័ន្ធផ្សេងទៀតដែលអាចប្រើប្រាស់ក្នុងការធ្វើសេចក្តីសម្រេចផ្តល់ឥណទាន។
- **ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់គ្រឹះស្ថាន បទបញ្ញា ស្តង់ដារ បច្ចេកវិទ្យានិងទិន្នន័យដែលផ្តល់លទ្ធភាពឲ្យមានការផ្លាស់ប្តូរព័ត៌មានឥណទានក្នុងចំណោមគ្រឹះស្ថានចំណុះច្បាប់ទាំងអស់ ។
- **សកម្មភាពចែករំលែកព័ត៌មានឥណទាន** សំដៅដល់សកម្មភាពទាំងឡាយណា ដែលស្ថិតនៅក្រោមវិសាលភាពនៃប្រកាសនេះ រួមមាន ការផ្តល់របាយការណ៍ឥណទាន និងការផ្តល់សេវាពាក់ព័ន្ធផ្សេងៗទៀត ។

- **អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន** សំដៅដល់អង្គភាពដែលធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ហើយទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា។
- **អ្នកផ្តល់ទិន្នន័យ** សំដៅដល់ ១/គ្រឹះស្ថានចំណុះច្បាប់ និង២/គ្រឹះស្ថានដទៃទៀតដែលផ្តល់ឥណទានតាមរូបភាពណាមួយ ហើយស្ម័គ្រចិត្តផ្តល់ព័ត៌មានដល់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ។
- **ព័ត៌មានឥណទានវិជ្ជមាន/ទិន្នន័យឥណទាន** សំដៅដល់ព័ត៌មាន ឬទិន្នន័យរបស់អតិថិជន រួមទាំងពាក្យស្នើសុំឥណទាន និងគុណភាពឥណទានសរុប ដូចជា ទំហំប្រាក់កម្ចី កាលវសាន្ត លក្ខខណ្ឌនៃការសងប្រាក់ និងវត្ថុបញ្ចាំ ជាដើម។
- **ព័ត៌មានឥណទានអវិជ្ជមាន** សំដៅដល់ព័ត៌មានទាក់ទងនឹងការហួសពេលកំណត់សង ការមិនបានសងប្រាក់កម្ចីតាមពេលកំណត់ ការលុបចោលប្រាក់កម្ចី ឬស្ថានភាពមិនសងប្រាក់នៃប្រតិបត្តិការឥណទានរវាងអតិថិជន និងអ្នកផ្តល់ទិន្នន័យ។
- **វិធានបដិការ** សំដៅដល់សំណុំវិធានដែលកំណត់ កម្រិតនៃការផ្លាស់ប្តូរព័ត៌មានទៅវិញទៅមក និងកិច្ចសហប្រតិបត្តិការរវាងអ្នកផ្តល់ទិន្នន័យ ។
- **ក្រុមប្រឹក្សាផ្តល់យោបល់** សំដៅដល់គណៈកម្មការផ្តល់យោបល់ដែលត្រូវបានបង្កើតឡើងដោយអ្នកផ្តល់ទិន្នន័យ អ្នកជំនាញឯករាជ្យ ក្រុមប្រឹក្សាភិបាល ធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរដែលពាក់ព័ន្ធដទៃទៀត។

## ជំពូកទី ២
## ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងការផ្តល់អាជ្ញាប័ណ្ណ

### ប្រការ ៣. ការបង្កើតប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ប្រព័ន្ធចែករំលែកព័ត៌មានឥណទានដែលនឹងបង្កើតឡើងត្រូវមាន ប្រសិទ្ធភាព សុវត្ថិភាព និងភាពអាចជឿទុកចិត្តបាន ដើម្បីធានាប្រព្រឹត្តកម្ម ស្មើភាព និងត្រឹមត្រូវសម្រាប់អ្នកផ្តល់ទិន្នន័យ និងអ្នកចូលរួមក្នុងទីផ្សារឥណទានផ្សេងទៀត ។

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ។

### ប្រការ ៤. ការហាមឃាត់

១. គ្មានបុគ្គលណាអាចធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ឬបង្ហាញដល់សាធារណជនថាខ្លួនធ្វើសកម្មភាពចែករំលែកព័ត៌មានឥណទាន ដោយពុំមានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជាឡើយ។

២. គ្មានបុគ្គលណា ត្រូវបានផ្តល់អាជ្ញាប័ណ្ណឲ្យអនុវត្តសកម្មភាពចែករំលែកព័ត៌មានឥណទានបានឡើយលើកលែងតែ នីតិបុគ្គលដែលត្រូវបានបង្កើតឡើងតាមច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម ។

៣. ប្រការនេះពុំអនុវត្តចំពោះធនាគារជាតិនៃកម្ពុជាដែលធ្វើប្រតិបត្តិការចែករំលែកព័ត៌មានឥណទានឡើយ។

## ប្រការ ៥. ការដាក់ពាក្យសុំអាជ្ញាប័ណ្ណ

នីតិបុគ្គលណាដែលមានបំណងចង់ប្រកបអាជីវកម្មលើសកម្មភាពចែករំលែកព័ត៌មានឥណទាន ត្រូវដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា តាមគំរូពាក្យសុំអាជ្ញាប័ណ្ណដែលបានកំណត់ ។

## ប្រការ ៦. ឯកសារសម្រាប់ដាក់ពាក្យសុំអាជ្ញាប័ណ្ណ

រាល់ពាក្យស្នើសុំអាជ្ញាប័ណ្ណត្រូវតែភ្ជាប់មកជាមួយនូវព័ត៌មាន និងឯកសារពាក់ព័ន្ធដូចខាងក្រោម ៖

ក. ឯកសារពាក់ព័ន្ធទាំងឡាយណាដែលទាក់ទងនឹងស្ថានភាពស្របច្បាប់របស់ក្រុមហ៊ុន

ខ. របាយការណ៍ទាក់ទងនឹងបទពិសោធន៍ពីមុនៗរបស់ស្ថាបនិកក្រុមហ៊ុន នៅក្នុងវិស័យធនាគារ និងឥណទាន រួមទាំងបញ្ជីឈ្មោះរបស់ភាគទុនិក ចំនួនប្រាក់ដែលបានដាក់វិនិយោគ និងការវិនិយោគនៅក្រុមហ៊ុនផ្សេងទៀត

គ. សមាសភាពរបស់ក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់

ឃ. ក្រុមអ្នកគ្រប់គ្រងត្រូវមានសញ្ញាប័ត្រសាកលវិទ្យាល័យ និងមានបទពិសោធន៍គ្រប់គ្រាន់ពាក់ព័ន្ធក្នុងទីផ្សារឥណទាន វិស័យធនាគារ ឬហិរញ្ញវត្ថុ

ង. រចនាសម្ព័ន្ធអង្គភាព ផែនការអាជីវកម្មបី (៣) ឆ្នាំ សម្រាប់ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ប្រព័ន្ធព័ត៌មានវិទ្យា នីតិវិធីផ្ទៃក្នុង និងសៀវភៅណែនាំប្រតិបត្តិការ

ច. ការសិក្សាពីភាពអាចធ្វើបានតាមផែនការអាជីវកម្ម ហេដ្ឋារចនាសម្ព័ន្ធសម្រាប់គាំទ្រដល់អាជីវកម្ម ឬកិច្ចព្រមព្រៀងពាក់ព័ន្ធនានាជាមួយអ្នកផ្តល់ទិន្នន័យផ្សេងទៀត

ឆ. រចនាសម្ព័ន្ធកម្មសិទ្ធិ និងអភិបាលកិច្ច រួមទាំងសមាសភាពនៃក្រុមប្រឹក្សាភិបាល និងលក្ខណៈវិនិច្ឆ័យ

ជ. ផែនការនិរន្តរភាព

ឈ. សំណើគោលនយោបាយកំណត់ថ្លៃ

ញ. ក្រមប្រតិបត្តិ និងវិធានពាក់ព័ន្ធផ្សេងទៀតសម្រាប់ដំណើរការប្រព័ន្ធ

ដ. សេចក្តីប្រកាសរបស់ភាគីពាក់ព័ន្ធ ដើម្បីអនុវត្តតាមក្រមប្រតិបត្តិនេះ ។

ធនាគារជាតិនៃកម្ពុជាអាចតម្រូវឲ្យផ្តល់ឯកសារចាំបាច់ផ្សេងទៀតសម្រាប់ការវាយតម្លៃលើពាក្យស្នើសុំនេះ។

## ប្រការ ៧. នីតិវិធីសម្រាប់ការដាក់ពាក្យសុំ

អ្នកដាក់ពាក្យសុំទាំងអស់ ត្រូវដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរ រួមជាមួយឯកសារពាក់ព័ន្ធដទៃទៀតមកធនាគារជាតិនៃកម្ពុជា ។

នៅក្នុងរយៈពេល ៩០ ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំគ្រប់គ្រាន់ រួមទាំងឯកសារពាក់ព័ន្ធ និងការបង់សោហ៊ុយសិក្សាសំណុំលិខិត ធនាគារជាតិនៃកម្ពុជានឹងជូនដំណឹងដល់អ្នកដាក់ពាក្យសុំជាលាយលក្ខណ៍អក្សរដោយបញ្ជាក់ពីការឯកភាព ឬការបដិសេធលើពាក្យសុំនោះ ។

# ជំពូកទី ៣
# គោលការណ៍នៃការប្រើប្រាស់ព័ត៌មាន

## ប្រការ ៨. ទិសដៅនៃសេវាចែករំលែកព័ត៌មាន

ការផ្តល់សេវាចែករំលែកព័ត៌មានឥណទានមានទិសដៅដូចខាងក្រោម៖

ក. វាយតម្លៃអំពីលទ្ធភាពសង និងការជំពាក់បំណុលរបស់អតិថិជននៅពេលដាក់ពាក្យស្នើសុំខ្ចីឥណទាន ឬប្រាក់កម្ចី

ខ. គាំទ្រធនាគារជាតិនៃកម្ពុជា ដែលមានតួនាទីត្រួតពិនិត្យដើម្បីតាមដានលំហូរឥណទានក្នុងប្រព័ន្ធហិរញ្ញវត្ថុ វិភាគទិន្នន័យសម្រាប់ធ្វើរបាយការណ៍អំពីស្ថិរភាពហិរញ្ញវត្ថុ និងត្រួតពិនិត្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ

គ. វាយតម្លៃហានិភ័យឥណទាន និង/ឬ ពិនិត្យឡើងវិញ ឬ ផ្តល់ឥណទាន ឬប្រាក់កម្ចី

ឃ. វាយតម្លៃហានិភ័យនៃប្រតិបត្តិការដែលមានការខកខានទូទាត់សងប្រាក់

ង. ផ្តល់សិទ្ធិឲ្យអតិថិជនមានលទ្ធភាពផ្ទៀងផ្ទាត់ ពីភាពត្រឹមត្រូវនៃព័ត៌មានរបស់ខ្លួនផ្ទាល់ដែលមានក្នុងរបាយការណ៍ឥណទាន

ច. វាយតម្លៃ ឬធ្វើសវនកម្មអំពីប្រសិទ្ធភាព ភាពអាចទុកចិត្តបាន និងការប្រតិបត្តិតាមបទប្បញ្ញត្តិជាធរមានចំពោះប្រព័ន្ធចែករំលែកព័ត៌មានឥណទាន។

ព័ត៌មានដែលមាននៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាននេះ មិនត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ក្រៅពីទិសដៅដូចមានចែងក្នុងប្រការនេះឡើយ លើកលែងតែទទួលបានការយល់ព្រមជាក់លាក់ជាមុនពីអតិថិជន ។

## ប្រការ ៩. ភារកិច្ចរបស់ភាគីពាក់ព័ន្ធក្នុងការធានាគុណភាពទិន្នន័យ

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យ ត្រូវប្រឹងប្រែងឲ្យអស់ពីលទ្ធភាពដើម្បីប្រាកដថា ព័ត៌មានអតិថិជនដែលបានប្រមូល ប្រើប្រាស់ និងបើកចំហ គឺជាព័ត៌មានដែលត្រឹមត្រូវ ពេញលេញ និងដែលបានធ្វើបច្ចុប្បន្នកម្ម ។ ទិន្នន័យនឹងត្រូវប្រមូលដោយប្រើប្រាស់មធ្យោបាយត្រឹមត្រូវ និងស្របច្បាប់ ហើយនឹងត្រូវបញ្ចូលតែព័ត៌មានចាំបាច់ ដូចជាអត្តសញ្ញាណដែលមានសុពលភាព និងសាវតាសងឥណទានរបស់អតិថិជន ។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យមានកាតព្វកិច្ចទទួលខុសត្រូវដូចខាងក្រោម៖

១. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវ៖

ក. បង្កើតឲ្យមាននីតិវិធីសមស្របដើម្បីធានាឲ្យបាននូវភាពពេញលេញ និងភាពត្រឹមត្រូវនៃព័ត៌មាន

ខ. ធានាថា ទិន្នន័យនឹងត្រូវបានធ្វើបច្ចុប្បន្នកម្មជាប្រចាំ ស្របតាមក្រមប្រតិបត្តិ

គ. បង្កើតយន្តការសមស្របសម្រាប់កែតម្រូវ និងលុបទិន្នន័យដើម្បីធានាថារាល់អ្នកប្រើប្រាស់ទាំងអស់ដែលបានចូលយកទិន្នន័យមិនត្រឹមត្រូវក្នុងរយៈពេលបី (៣) ខែ កន្លងមក ត្រូវបានជូន

ដំណឹងគ្រប់គ្រាន់អំពីកំហុស និងកែតម្រូវទិន្នន័យដោយស្របទៅតាមពេលកំណត់ជាក់លាក់ ដូចមានចែងនៅក្នុងក្រមប្រតិបត្តិ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថាអ្នកប្រើប្រាស់ទាំងអស់ ដែលមានសិទ្ធិប្រើប្រាស់ទិន្នន័យ ក្នុងរយៈពេលបី (៣) ខែ ចុងក្រោយនេះបានដឹងពីកំហុស និងទទួលបានព័ត៌មានត្រឹមត្រូវវិញ ហើយច្បាប់ចម្លងនៃទិន្នន័យនោះក៏នឹងត្រូវផ្ញើទៅឲ្យអតិថិជនផងដែរ

ឃ. ទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ អតិថិជន នូវកំហុសទិន្នន័យនានាដែលបានកើតឡើងក្នុងពេលដំណើរការ ឬចែកចាយទិន្នន័យឥណទានដែលបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់។ អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវ៖

- កែតម្រូវទិន្នន័យភ្លាមៗ និងត្រូវបង្កើតយន្តការសមស្របដើម្បីធានាថា អ្នកប្រើប្រាស់ទាំងអស់ដែលបានប្រើប្រាស់ទិន្នន័យក្នុងរយៈពេលបី (៣) ខែ ចុងក្រោយបានដឹងពីកំហុសនេះ និងទទួលបានព័ត៌មានត្រឹមត្រូវវិញបន្ទាប់ពីបានធ្វើបច្ចុប្បន្នកម្ម
- ទទួលរបាយការណ៍ដែលបានធ្វើបច្ចុប្បន្នកម្មនោះ ដោយប្រគល់ទៅឲ្យអតិថិជនតាម អាសយដ្ឋានដែលមាននៅក្នុងឯកសារដែលគ្រប់គ្រងដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន
- ទទួលខុសត្រូវចំពោះការប្តឹងទាមទាររបស់អតិថិជនពីកំហុស ដែលអាចបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិស័ព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់
- ប្រឹងប្រែងតាមដែលអាចធ្វើបាន ដើម្បីកាត់បន្ថយការខូចខាតនានាដែលទទួលរងដោយអតិថិជនដោយសារតែទិន្នន័យមិនត្រឹមត្រូវនេះ ។

ង. ទទួលខុសត្រូវចំពោះអ្នកផ្តល់ទិន្នន័យ អ្នកប្រើប្រាស់ប្រតិស្រុតិ ធនាគារជាតិនៃកម្ពុជា ឬតតិយជនណាមួយ សម្រាប់រាល់ការទាមទារពាក់ព័ន្ធនឹងការពន្យារពេល ការរំខាន ឬការខកខានមិនបានផ្តល់ព័ត៌មានឥណទាន ឬរបាយការណ៍ស្ថិតិ លើកលែងតែហេតុការណ៍ទាំងនោះបណ្តាលមកពីការបង្គាប់បញ្ជារបស់រាជរដ្ឋាភិបាល ការធ្វើវិទ្ធង្សនា កុប្បកម្ម ការបំផ្លាញ ទ្រព្យសម្បត្តិជាសាធារណៈ ការបដិសេធសេវាពីអ្នកផ្តល់សេវាអ៊ិនធឺណេត (ISP) ឬរាល់មូលហេតុដទៃទៀតដែលហួសពីសមត្ថកិច្ចរបស់អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ច. មិនត្រូវផ្ទេរ លក់ ឬជួលរាល់ព័ត៌មានឥណទានដែលត្រូវបានបញ្ជូនមក ដោយអ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ប្រតិស្រុតិ

២. អ្នកផ្តល់ទិន្នន័យ ត្រូវទទួលខុសត្រូវចំពោះ៖

ក. ព័ត៌មានមិនត្រឹមត្រូវណាដែលខ្លួនបានផ្តល់ឲ្យអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

ខ. ការប្តឹងទាមទាររបស់អតិថិជនអំពីកំហុសនានា ដែលអាចបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់កិត្តិស័ព្ទហិរញ្ញវត្ថុរបស់អតិថិជន ដែលជាហេតុបណ្តាលមកពីការធ្វេសប្រហែសធ្ងន់ធ្ងរ ឬ

ការប្រព្រឹត្តដោយមិនយកចិត្តទុកដាក់ ស្របតាមការសម្រេចដែលធ្វើឡើងក្រោមយន្តការដំណោះស្រាយវិវាទ ដូចមានចែងក្នុងប្រការ២៦ នៃប្រកាសនេះ

ឥ. ការខិតខំកាត់បន្ថយការខូតខាតរបស់អតិថិជនដែលបណ្តាលមកពីទិន្នន័យមិនត្រឹមត្រូវតាមរយៈការបង្កើតឲ្យមាននូវគោលនយោបាយ និងតម្រូវការនីតិវិធីចាំបាច់នានា ។

អ្នកផ្តល់ទិន្នន័យនីមួយៗ ត្រូវមានវិធានក្នុងការសម្រេចផ្តល់ឥណទានរបស់ខ្លួន។ ព័ត៌មានឥណទាន និងសេវាដទៃទៀតដែលផ្តល់ដោយប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវចាត់ទុកជាឧបករណ៍មួយសម្រាប់ដំណើរការនៃការសម្រេចលើហានិភ័យឥណទាន ប៉ុន្តែការសម្រេចទាំងនោះមិនត្រូវធ្វើឡើងដោយគ្រាន់តែផ្អែកទៅលើមូលដ្ឋានព័ត៌មានឥណទានដែលបានទទួលពីប្រព័ន្ធចែករំលែកព័ត៌មានឥណទានមួយប៉ុណ្ណោះទេ។

## ប្រការ ១០. សុវត្ថិភាពទិន្នន័យ

អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងអ្នកផ្តល់ទិន្នន័យត្រូវធានាសុវត្ថិភាពនិងភាពត្រឹមត្រូវនៃដាតាបេស្ស (Database) ឲ្យបានគ្រប់ពេលវេលា។ ដើម្បីបង្ការការប្រើប្រាស់មិនត្រឹមត្រូវ ឬការចូលយកព័ត៌មានទិន្នន័យ ប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតទិន្នន័យ រាល់ដំណើរការចាំបាច់នានាត្រូវមានវិធានការដូចខាងក្រោម ៖

១. ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមានប្រព័ន្ធ កិច្ចដំណើរការ និងនីតិវិធីក្នុងការទាញយកទិន្នន័យមកវិញ និងត្រូវមានផែនការស្តារគ្រោះមហន្តរាយ ដើម្បីទប់ស្កាត់ការបាត់បង់ ឬការខូចខាតទិន្នន័យ ។

ក. ការចូលទៅក្នុងដាតាបេស្ស ត្រូវបានអនុញ្ញាតចំពោះតែអ្នកប្រើប្រាស់ប្រតិស្រុតិ ប៉ុណ្ណោះ

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតយន្តការសមស្របដើម្បីធានាថាទិន្នន័យត្រូវបានឲ្យប្រើប្រាស់សម្រាប់តែទិសដៅដែលបានអនុញ្ញាតប៉ុណ្ណោះ ឬសម្រាប់ទិសដៅស្របច្បាប់ផ្សេងទៀត ដោយមានការយល់ព្រមពីអតិថិជន ស្របតាមប្រការ ៨ នៃប្រកាសនេះ ។

២. អ្នកផ្តល់ទិន្នន័យត្រូវធានាឲ្យមានជាស្រេចនូវនីតិវិធី គោលនយោបាយ និងវិធានការសុវត្ថិភាពគ្រប់គ្រាន់ ។ គោលនយោបាយវិធានការសុវត្ថិភាពសម្រាប់ប្រតិបត្តិការប្រព័ន្ធចែករំលែកព័ត៌មាន ត្រូវតែអនុម័តដោយក្រុមប្រឹក្សាភិបាលនៃអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងធនាគារជាតិនៃកម្ពុជា ។ វិធានការដែលបានអនុម័ត ត្រូវឆ្លុះបញ្ចាំងពីលក្ខណៈបច្ចេកទេស រចនាសម្ព័ន្ធចាត់តាំង និងបច្ចេកវិទ្យា ។

## ប្រការ ១១. រយៈពេលរក្សាទុកទិន្នន័យ

១. ព័ត៌មានប្រមូលដោយប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបានបែងចែកក្នុងចំណោមអ្នកផ្តល់ទិន្នន័យសម្រាប់រយៈពេលដប់ (១០) ឆ្នាំ គិតពីថ្ងៃឥណទានត្រូវបានទូទាត់សងគ្រប់ចំនួន ក្នុងករណីព័ត៌មានវិជ្ជមាន ។

២. ទិន្នន័យអំពីសេចក្តីសម្រេចរបស់តុលាការ ត្រូវបែងចែកក្នុងរយៈពេលបី (៣) ឆ្នាំ គិតចាប់ពីថ្ងៃដែលសេចក្តីសម្រេចនោះចូលជាស្ថាពរ ។

៣. ទិន្នន័យក្ស័យធន នឹងត្រូវបែងចែកក្នុងរយៈពេលប្រាំ (៥) ឆ្នាំ គិតពីថ្ងៃប្រកាសក្ស័យធន ។

៤. ព័ត៌មានអវិជ្ជមាន នឹងត្រូវបែងចែកក្នុងរយៈពេលបី (៣) ឆ្នាំ គិតពីថ្ងៃកំណត់សងប្រាក់ ។

## ប្រការ ១២. សិទ្ធិអតិថិជន

ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងភាគីពាក់ព័ន្ធត្រូវធានាថា៖

ក. សិទ្ធិរបស់បុគ្គលទៅលើទិន្នន័យរបស់ខ្លួនត្រូវបានគោរព

ខ. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតឲ្យមានផ្នែកមួយដែលមាននីតិវិធី និងវិធានច្បាស់លាស់ដើម្បីដោះស្រាយការតវ៉ា និងសំណើរបស់បុគ្គលដែលពាក់ព័ន្ធនឹងទិន្នន័យរបស់ខ្លួន

គ. ទិន្នន័យពាក់ព័ន្ធនឹងនិន្នាការនយោបាយ ជំនឿសាសនា ពណ៌សម្បុរ ពូជសាសន៍ និងព័ត៌មានឯកជនរបស់បុគ្គល មិនត្រូវបានប្រមូលឬរក្សាទុកនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ

ឃ. ទិន្នន័យត្រូវបានប្រមូលសម្រាប់តែប្រើប្រាស់ក្នុងគោលបំណងដូចមានចែងក្នុងប្រការ ៨ នៃប្រកាសនេះ។ ទិន្នន័យដែលបានប្រមូល ឬប្រើប្រាស់ក្នុងគោលបំណងផ្សេងក្រៅពីមានចែងក្នុងប្រការ ៨ នេះ ត្រូវមានការយល់ព្រមច្បាស់លាស់ពីអតិថិជន ។

# ជំពូកទី ៤
# អ្នកផ្តល់ទិន្នន័យ

## ប្រការ ១៣. គ្រឹះស្ថានចំណុះច្បាប់

១. គ្រឹះស្ថានចំណុះច្បាប់ត្រូវចូលរួមផ្តល់រាល់ព័ត៌មានឥណទានទាំងវិជ្ជមាន និងអវិជ្ជមានទៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានជារៀងរាល់ខែ។ ការខកខានមិនបានចូលរួមផ្តល់ទិន្នន័យ និង/ឬការខកខានមិនបានចូលប្រើប្រាស់ទិន្នន័យ នឹងត្រូវរងការដាក់ទណ្ឌកម្មដូចមានចែងក្នុងច្បាប់ជាធរមាន ។

២. ការយល់ព្រមរបស់អតិថិជន គឺជាការចាំបាច់សម្រាប់ការប្រមូលទិន្នន័យ និងការចូលប្រើប្រាស់ទិន្នន័យ។ ធនាគារជាតិនៃកម្ពុជា នឹងរៀបចំគំរូនៃកិច្ចព្រមព្រៀងជាស្តង់ដារសម្រាប់ឲ្យគ្រឹះស្ថានចំណុះច្បាប់ប្រើប្រាស់។

៣. គ្រឹះស្ថានចំណុះច្បាប់ មានរយៈពេលប្រាំបួន (៩) ខែ ក្នុងការដាក់ឲ្យដំណើរការប្រព័ន្ធផ្តល់ទិន្នន័យប្រចាំខែរបស់ខ្លួន ។

៤. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងផ្តល់សេវាស្មើភាពចំពោះអ្នកចូលរួមទាំងអស់ ដោយគ្មានការរើសអើងចំពោះអ្នកផ្តល់ទិន្នន័យឡើយ ។

### ប្រការ ១៤. អ្នកប្រើប្រាស់និងអ្នកផ្តល់ទិន្នន័យផ្សេងទៀត

១. គ្រឹះស្ថានក្រៅពីគ្រឹះស្ថានចំណុះច្បាប់ អាចចូលរួមផ្តល់ និងចូលប្រើប្រាស់ទិន្នន័យនៅក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន នៅពេលណាដែលទទួលបានការយល់ព្រមជាមុនពីអគ្គនាយកធនាគារជាតិនៃកម្ពុជា។

២. អ្នកប្រើប្រាស់និងអ្នកផ្តល់ទិន្នន័យទាំងអស់ ទោះបីស្ថិត ឬមិនស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ធនាគារជាតិនៃកម្ពុជា ត្រូវស្ថិតនៅក្រោមវិធាន កាតព្វកិច្ច និងទណ្ឌកម្ម ដូចមានចែងនៅក្នុងប្រកាសនេះ។

៣. យោងតាមវិធានបដិការ គ្រឹះស្ថានដែលមិនបានរាយការណ៍រាល់ព័ត៌មានដែលតម្រូវ នឹងមិនត្រូវបានអនុញ្ញាតឲ្យទទួលព័ត៌មានទាំងឡាយណាដែលបានបញ្ចូលក្នុងប្រព័ន្ធចែករំលែកព័ត៌មានឥណទានដោយអ្នកផ្តល់ទិន្នន័យផ្សេងទៀតឡើយ ។

៤. ធនាគារជាតិនៃកម្ពុជាអាចតម្រូវឲ្យមានការចូលរួមរបស់អ្នកផ្តល់ទិន្នន័យថ្មី នៅពេលដែលធនាគារជាតិនៃកម្ពុជាយល់ឃើញថាសកម្មភាពរបស់គេមានភាពចាំបាច់នៅក្នុងទីផ្សារឥណទានកម្ពុជា ។

## ជំពូកទី ៥
## ការគ្រប់គ្រងប្រព័ន្ធចែករំលែកព័ត៌មានឥណទាន

### ប្រការ ១៥. អភិបាលកិច្ចសាជីវកម្ម

១. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវដឹកនាំដោយក្រុមប្រឹក្សាភិបាល ដែលមានសមាជិកយ៉ាងតិចចំនួនប្រាំពីរ (៧) រូប ដែលក្នុងនោះសមាជិកមួយ (១) រូប ជាតំណាងមកពីធនាគារជាតិនៃកម្ពុជា និងមួយ (១) រូបទៀត ជាអភិបាលឯករាជ្យ ។

២. សមាជិកក្រុមប្រឹក្សាភិបាលត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ អំពីប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ។ គ្មានជនណាម្នាក់ ត្រូវតែងតាំងជាសមាជិកក្រុមប្រឹក្សាភិបាលនៃប្រព័ន្ធចែករំលែកព័ត៌មានឥណទានឡើយ ប្រសិនបើជននោះត្រូវបានផ្តន្ទាទោសពី ៖

ក. បទឧក្រិដ្ឋណាមួយ

ខ. បទលួច បទក្លែងបន្លំ ឬបទរំលោភលើសេចក្តីទុកចិត្ត

គ. បទគៃបំបាត់

ឃ. ព្រឹទ្ធិកម្ម

ង. បទសំអាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម

ច. ការចេញមូលប្បទានបត្រគ្មានសាច់ប្រាក់

ឆ. ការក្ស័យធនផ្ទាល់ខ្លួន ការដាក់ទ្រព្យសម្បត្តិក្រោមអភិបាលបណ្តោះអាសន្ន ឬការជម្រះបញ្ជីទ្រព្យសម្បត្តិ។

៣. នាយកប្រតិបត្តិ ត្រូវតែងតាំងដោយក្រុមប្រឹក្សាភិបាល។ គ្មានជនណាម្នាក់នឹងត្រូវបានតែងតាំងជានាយកប្រតិបត្តិទេ ប្រសិនបើជននោះជា ៖

ក. ជនដែលទទួលទោសពីបទឧក្រិដ្ឋណាមួយ

ខ. អនីតិជន ឬអសមត្ថជនតាមផ្លូវច្បាប់

គ. ជនដែលទទួលទោសពីបទលួច ឬក្លែងបន្លំដែលបណ្តាលឲ្យមានការខាតបង់ផ្នែកហិរញ្ញវត្ថុ

ឃ. ជនដែលត្រូវបានបណ្តេញចេញពីមុខតំណែង ដោយសារតែបានយកមុខតំណែងទៅប្រើប្រាស់ក្នុងគោលបំណងមិនត្រឹមត្រូវ ឬបានប្រព្រឹត្តអំពើពុករលួយក្នុងអំឡុងពេលដប់ (១០) ឆ្នាំចុងក្រោយនេះ

ង. ជនដែលត្រូវបានផ្តន្ទាទោសពីបទរំលោភលើសេចក្តីទុកចិត្ត និង

ច. នាយកប្រតិបត្តិ ឬសមាជិកក្រុមប្រឹក្សាភិបាលរបស់អ្នកប្រើប្រាស់ និងអ្នកផ្តល់ទិន្នន័យ ។

៤. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបង្កើតផ្នែកមួយ ដើម្បីអនុវត្តការគោរពសិទ្ធិអតិថិជន ប្រតិបត្តិការរបស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងវិធានការសុវត្ថិភាព ។

៥. ក្រុមប្រឹក្សាភិបាលត្រូវធានាថា ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្ន និងអនុលោមតាមបទប្បញ្ញត្តិជាធរមាន ។

## ជំពូកទី ៦
## ដំណើរការនៃប្រព័ន្ធ

### ប្រការ ១៦. ប្រភពទិន្នន័យ

១. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាននឹងប្រមូល បញ្ចូល និងផ្សព្វផ្សាយព័ត៌មានឥណទាន និងទិន្នន័យពាក់ព័ន្ធនឹងបុគ្គល និងសហគ្រាស ពីប្រភពដូចខាងក្រោម ៖

ក. គ្រឹះស្ថានចំណុះច្បាប់ អ្នកប្រើប្រាស់ និងអ្នកផ្តល់ទិន្នន័យផ្សេងទៀត

ខ. ព័ត៌មានពីប្រភពផ្សេងទៀតដែលមានជាសាធារណៈតាមមធ្យោបាយស្របច្បាប់ ។

២. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទានអាចមានលទ្ធភាពប្រើប្រាស់ព័ត៌មានដែលអាចរកបានជាសាធារណៈ និងពីប្រភពផ្សេងទៀតដូចខាងក្រោម ៖

ក. ស្ថាប័ន ឬអង្គភាពទទួលបន្ទុកចុះបញ្ជីពាណិជ្ជកម្ម ចុះបញ្ជីអចលនវត្ថុ និងចុះបញ្ជីកម្មសិទ្ធិលើទ្រព្យសម្បត្តិផ្សេងទៀត

ខ. ស្ថាប័ន ឬអង្គភាពទទួលបន្ទុករក្សាទុកឯកសារសំគាល់អត្តសញ្ញាណ ដូចជាអត្តសញ្ញាណប័ណ្ណសៀវភៅគ្រួសារ លិខិតឆ្លងដែន និងលេខបង់ពន្ធ ជាដើម ។

៣. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន អាចប្រមូលទិន្នន័យពីសេចក្តីសម្រេចរបស់តុលាការ និងដំណើរការក្ស័យធនបើមាន តាមរយៈមធ្យោបាយស្របច្បាប់។

## ប្រការ ១៧. ការប្រមូល និងការចែកចាយ

១. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវប្រមូល រៀបចំ និងរក្សាទុកព័ត៌មានឥណទានដែលទទួលបានពីអ្នកផ្តល់ទិន្នន័យ និងពីប្រភពផ្សេងទៀតតាមដែលអាចធ្វើទៅបានរាប់បញ្ចូលទាំងសេចក្តីណែនាំអំពីប្រតិបត្តិការក្នុងការការពារទិន្នន័យពី ការប្រើប្រាស់មិនត្រឹមត្រូវ ការប្រើប្រាស់ដោយគ្មានការអនុញ្ញាត ការបាត់បង់ ឬការខូចខាតនៃប្រព័ន្ធ។ ប្រព័ន្ធចែករំលែកព័ត៌មានឥណទានត្រូវមាននីតិវិធីត្រួតពិនិត្យគុណភាព ដើម្បីធានាឲ្យបាននូវនិរន្តរភាពសេវាកម្ម ។

២. អ្នកផ្តល់ទិន្នន័យ ត្រូវផ្តល់សំពៀតឥណទានទាំងអស់ដោយអនុលោមតាមទម្រង់ និងគំរូដែលកំណត់ដោយអ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដោយមានការព្រមព្រៀងជាមួយក្រុមប្រឹក្សាផ្តល់យោបល់ ។ ទម្រង់ដំបូងនឹងត្រូវយកតាមទម្រង់ដែលមានក្នុងឧបសម្ព័ន្ធ ១ (ទម្រង់ឯកសារ)។ ទម្រង់ឯកសារនេះចែកចេញជាពីរផ្នែកៈ ផ្នែកទី១ ចែងពីព័ត៌មានស្តីពីអត្តសញ្ញាណរបស់អ្នកខ្ចី និងអ្នកធានា និងផ្នែកទី២ ចែងពីទិន្នន័យនៃប្រតិបត្តិការឥណទាន ។

៣. អ្នកផ្តល់ទិន្នន័យ ត្រូវផ្តល់ឯកសារដំបូងក្នុងរយៈពេលកៅសិប (៩០) ថ្ងៃ គិតចាប់ពីថ្ងៃដែលបានទទួលដំណឹងអំពីកាលបរិច្ឆេទចាប់ផ្តើម ។

ក. ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវបញ្ចូលទិន្នន័យពាក់ព័ន្ធស្របតាមទម្រង់ឯកសារ ដែលបានទទួលពីអ្នកផ្តល់ទិន្នន័យក្នុងរយៈពេលប្រាំ (៥) ថ្ងៃធ្វើការ បន្ទាប់ពីបានទទួលទិន្នន័យនោះ

ខ. អ្នកផ្តល់ទិន្នន័យទាំងអស់ ត្រូវផ្តល់ព័ត៌មានឥណទានដែលបានធ្វើបច្ចុប្បន្នកម្មរបស់ខ្លួនជារៀងរាល់ខែ យ៉ាងយូរបំផុតត្រឹមថ្ងៃទី៥នៃខែបន្ទាប់

គ. សំណុំឯកសារដែលផ្តល់ដោយអ្នកប្រើប្រាស់ត្រូវផ្តល់ជូនតាមទម្រង់ ដែលបង្កើតដោយក្រុមប្រឹក្សាភិបាល និងឯកភាពដោយក្រុមប្រឹក្សាផ្តល់យោបល់ ។

៤. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវទទួលខុសត្រូវចំពោះដាតាបេស្ស (Database) របស់ប្រព័ន្ធចែករំលែកព័ត៌មានឥណទាន និងត្រូវផ្តល់សេវាព័ត៌មានឥណទានដល់គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ និងអ្នកប្រើប្រាស់ផ្សេងទៀត អនុលោមតាមប្រកាសនេះ ក្រមប្រតិបត្តិ ឬបទប្បញ្ញត្តិជាធរមានរបស់ធនាគារជាតិនៃកម្ពុជា ។

៥. អ្នកផ្តល់សេវាប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ត្រូវទទួលខុសត្រូវចំពោះការលេចធ្លាយទិន្នន័យដោយសារការខូចខាតនៃប្រព័ន្ធ ឬការប្រើប្រាស់ទិន្នន័យមិនសមស្របពីសំណាក់និយោជិតរបស់ខ្លួន។

៦. គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត មិនត្រូវលក់ ឬលាតត្រដាងព័ត៌មានឥណទានដល់តតិយជនឡើយ។ គ្រឹះស្ថានចំណុះច្បាប់ អ្នកផ្តល់ទិន្នន័យ ឬអ្នកប្រើប្រាស់ផ្សេងទៀត មិនត្រូវប្រើប្រាស់ព័ត៌មានដែលទទួលបានពីប្រព័ន្ធចែករំលែកព័ត៌មានឥណទាន ដើម្បីផ្តល់សេវាកម្មឲ្យតតិយជន ឬធ្វើយុទ្ធនាការស្វែងរកទីផ្សារ ក្រៅពីអតិថិជនរបស់ខ្លួនឡើយ ។

